# របាយការណ៍វឌ្ឍន៍ភាព ស្តីពី
# លទ្ធផល នៃការអនុវត្តន៍គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ច

ពីខែមករា ដល់ ខែមីនា ឆ្នាំ២០២១

**១-ក្រុមហ៊ុនឈ្មោះ** ៖ ហ្រ្គែនឌីស ធីមប៊ើរ អិលធីឌី

**២-ទីតាំងនិងទំហំផ្ទៃដី** ៖ ស្រុកភ្នំស្រួច និងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ មានទំហំផ្ទៃដីសរុប ៧.៨៩៦,១១ ហិកតា

**៣-ប្រភេទដំណាំ** ៖ ដើមឈើម៉ៃសាក់

**៤-ផែនការមេ** ៖ ក្រសួង ☑ ឬ ខេត្ត ☐

- ផែនការមេថ្មី៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុម័តរួចរាល់ តាមលិខិតលេខ ២០២៤ កសក ចុះថ្ងៃទី២៧ ខែកុម្ភៈឆ្នាំ២០២០
- ផែនការមេចាស់៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុម័តរួចរាល់ តាមលិខិតលេខ ៣២៥៩/៣៣៦ កសក.រផ.ផក ចុះថ្ងៃទី០២ ខែ មិថុនា ឆ្នាំ ២០១០។

**៥-ការចុះបញ្ជីដីរដ្ឋ** ៖ បានទទួលប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ចំនួន ១៧ ក្បាលដី

- អនុវត្តរួចរាល់ ☑ ស្នើផ្តល់ឯកសារ (១៧ ប្លង់ដី
- កំពុងអនុវត្ត ☐ ដល់ណាស្នើបញ្ជាក់ និងផ្តល់ឯកសារ
- មិនបានអនុវត្ត ☐ មូលហេតុ

**៦-អនុបយោគ** ៖ វិញ្ញាបនប័ត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច ចំនួន ១៧ ប័ណ្ណ

- បានអនុវត្តរួចរាល់ ☑ ស្នើផ្តល់ឯកសារ (និងអនុក្រឹត្យលេខ១៧៥ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧)
- កំពុងអនុវត្ត ☐ ដល់ណាស្នើបញ្ជាក់ និងផ្តល់ឯកសារ
- មិនបានអនុវត្ត ☐ មូលហេតុ

**៧-របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន៖**

- បានអនុវត្តរួចរាល់ ☑
  - របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ពេញលេញ៖ អនុម័តរួចរាល់តាមលិខិតលេខ ១៥៦២ សជណ ប.ស្ក ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៩
  - របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានបឋម៖ អនុម័តរួចរាលតាមលិខិតលេខ ១៧២ ស.ជ.ណ ប.ស្ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤ របស់ក្រសួងបរិស្ថាន។
- កំពុងអនុវត្ត ☐ ដល់ណាស្នើបញ្ជាក់ និងផ្តល់ឯកសារ
- មិនបានអនុវត្ត ☐ មូលហេតុ

**៨-លិខិតអនុញ្ញាតឲ្យឈូសឆាយ៖**

- មាន ☐ គ្មាន ☑ អនុញ្ញាតដោយក្រសួង ឬខេត្ត (ក្នុងត្រីមាសទី១ ឆ្នាំ២០២១នេះ)
  - លិខិតលេខ.១៨៨ កសក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៨ របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ នៅអនុតំបន់ទី៧ ៨ ៩ និង១០ លើផ្ទៃទំហំសរុប ១២១២ហិកតា
  - លិខិតលេខ.៤០១២/២៥៦ កសក.នផ.ផក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅអនុតំបន់ទី៧, ៨ និង៩ លើផ្ទៃដីទំហំ ២០០០ហិកតា
  - លិខិតលេខ.៣២៥៩/៣៣៦ កសក.នផ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅអនុតំបន់ទី១ លើផ្ទៃដីទំហំ ៤០៧ហិកតា

**៩-ទីតាំង និងទំហំផ្ទៃដីដែលអនុញ្ញាតឲ្យឈូសឆាយជាំផុះ៖**

- **អនុតំបន់ទី 0 ទំហំ 0 ហិកតា**

**១០-លទ្ធផលអនុវត្តបាន៖** (ប្រសិនបើមានអនុវត្តច្រើនអនុតំបន់ស្នើរាយការណ៍តាមអនុតំបន់នីមួយៗ)

**១០.១-ការឈូសឆាយ-ដាំដុះ**

- ឈូសឆាយបាន/ឈូសឆាយឡើងវិញ ០០ ហិកតា ក្នុងអនុតំបន់ទី
- ដាំដុះបាន/ដាំឡើងវិញ ០ ហិកតា ប្រភេទដំណាំ ០ ក្នុងអនុតំបន់ទី
- ផ្ទៃដីនៅសល់មិនទាន់ដាំ ១២១,១៥ហិកតា ក្នុងអនុតំបន់ទី ៦ និង១០ (១១១,១០ហត សល់ពីឆ្នាំ២០១៨ និង១០,០៥ហត សល់ពីឆ្នាំ២០១៧)
- ផ្ទៃដីមិនអាចដាំដុះបាន ០ ហិកតា ក្នុងអនុតំបន់ទី ០ ស្នើបញ្ជាក់ពីមូលហេតុដីមិនអាចដាំបាន៖ ។ (*ស្នើបញ្ជាក់ចំនុចនិយាមកាទីតាំងដាំដុះ និងភ្ជាប់មកជាមួយផែនទីតំបន់ដាំដុះ*)

**១០.២-ការងារសាងសង់៖**

| **ប្រភេទសំណង់** | **ចំនួន** | **ប្រវែង/ទំហំ (គម ឬម²)** | **សម្គាល់** |
|---|---|---|---|
| សាងសង់ផ្លូវក្នុងតំបន់ដីសម្បទានចំនួន | 0 | 0 | |
| សាងសង់ផ្លូវក្រៅ តំបន់ដីសម្បទានចំនួន | 0 | 0 | |
| ជួសជុលផ្លូវក្នុង តំបន់ដីសម្បទានចំនួន | ០៧ | ១៦.៩២គម | |

**១០.៣-ការងារប្រមូលសំណល់ឈើពីការឈូសឆាយក្នុងតំបន់សម្បទាន៖**

- ឈើមូលសរុប គ្មាន ម³ បង់ថ្លៃសួយសាររួច គ្មាន ម³
- ឈើមូលសរុបនៅសល់មិនទាន់បង់ គ្មាន ម³ បញ្ជាក់មូលហេតុ៖ គ្មានការឈូសឆាយនោះទេ
- កូនឈើសរុប គ្មាន ដើម បង់ថ្លៃសួយសាររួច គ្មាន ដើម
- កូនឈើសរុបមិនទាន់បង់ គ្មាន ដើម បញ្ជាក់មូលហេតុ៖ គ្មានការឈូសឆាយនោះទេ
- អុសសរុប គ្មាន ស្ទែរ បង់ថ្លៃសួយសាររួច គ្មាន ស្ទែរ
- អុសសរុបមិនទាន់បង់ គ្មាន ស្ទែរ បញ្ជាក់មូលហេតុ៖ គ្មានការឈូសឆាយនោះទេ

**១០.៤-ការប្រើប្រាស់កម្លាំងពលកម្ម៖**

- បុគ្គលិកខ្មែរសរុប ៥៦ នាក់ ប្រាក់បៀវត្សប្រចាំខែក្នុងម្នាក់ ៥១៨,៦៥ដុល្លារអាមេរិក
- បុគ្គលិកបរទេសសរុប ០ នាក់ ប្រាក់បៀវត្សប្រចាំខែក្នុងម្នាក់ ០ ដុល្លារអាមេរិក
- កម្មករខ្មែរអចិន្ត្រៃយ៍សរុប ៣០ នាក់ ប្រាក់បៀវត្សប្រចាំខែក្នុងម្នាក់ ១៩២ ដុល្លារអាមេរិក
- កម្មករបរទេសសរុប គ្មាន នាក់ ប្រាក់បៀវត្សប្រចាំខែក្នុងម្នាក់ គ្មាន
- កម្មករបណ្តែតសរុប ១៥ នាក់ ប្រាក់បៀវត្សប្រចាំខែក្នុងម្នាក់ $៧,៣០/ថ្ងៃ

**១០.៥-ផ្ទៃដីប្រមូលផល៖**

- ទំហំផ្ទៃដីប្រមូលផលដំណាំចម្បង
  - ១. ប្រភេទដំណាំ គ្មាន ចំនួន គ្មាន ហិកតា អនុតំបន់ទី គ្មាន
  - ២.ប្រភេទដំណាំ គ្មាន ចំនួន គ្មាន ហិកតា អនុតំបន់ គ្មាន
- ទំហំផ្ទៃដីប្រមូលផលបន្ទាប់បន្សំ
  - ១.ដំណាំ គ្មាន ចំនួន គ្មាន ហិកតា អនុតំបន់ គ្មាន
  - ២.ដំណាំ គ្មាន ចំនួន គ្មាន ហិកតា អនុតំបន់ គ្មាន

**១០.៦-ការប្រើប្រាស់ផល-ផលិតផល៖**

- បរិមាណផល-ផលិតផលទទួលបានតាមប្រភេទដំណាំ៖
  - ១. ដំណាំ គ្មាន ចំនួន គ្មាន តោន
  - ២. ដំណាំ គ្មាន ចំនួន គ្មាន តោន

- បរិមាណនិងប្រភេទផល-ផលិតផលសរុបទទួលបានៈ
  - ១. ដំណាំ គ្មាន ចំនួន គ្មាន តោន
  - ២. ដំណាំ គ្មាន ចំនួន គ្មាន តោន
- បរិមាណនិងប្រភេទផល-ផលិតផលនាំចេញៈ
  - ១. ដំណាំ គ្មាន ចំនួន គ្មាន តោន ទៅប្រទេស
  - ២. ដំណា គ្មាន ចំនួន គ្មាន តោន ទៅប្រទេស
- បរិមាណនិងប្រភេទផល-ផលិតផលប្រើប្រាស់ក្នុងស្រុកៈ
  - ១. ដំណាំគ្មាន ចំនួន គ្មាន តោន ទៅប្រទេស
  - ២. ដំណាំ គ្មាន ចំនួន គ្មាន តោន ទៅប្រទេស

**១០.៧-ការងារផ្សេងៗ**

- ល្បាតការពារ បង្ការ ទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃ ឬចម្ការឈើ
- ត្រាក់ទ័រភ្ជួរផាល៧ ការពារភ្លើងឆេះចម្ការបាន ៧២ ហិកតា
- ឈូសសម្អាតផ្លូវភ្លើង និងក្រវ៉ាត់ជុំវិញចម្ការឈើដោយគ្រឿងចក្រ Bulldozer បានប្រវែង ១៣៦,៧ គីឡូម៉ែត្រ

**១១.ការបង់ថ្លៃឈ្នួលសម្បទានៈ** មាន ☑ គ្មាន ☐ បើមានៈ

- ទទួលបានលិខិតជូនដំណឹងលេខ ១៩៨២ កសក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ស្តីពីកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនរដ្ឋ ឆ្នាំ២០២០ (២០២០-២០២១)
- បានបង់រួចសម្រាប់ឆ្នាំ២០១៩ (២០១៩-២០២០) នូវទឹកប្រាក់សរុបចំនួន ៤១ ០៨៣,៦១ ដុល្លារអាមេរិក នៅធនាគារជាតិនៃកម្ពុជា និងធនាគារអេស៊ីលីដា ភីអិលស៊ី
- បានបង់រួចសម្រាប់ឆ្នាំ២០១៨ (២០១៨-២០១៩) នូវទឹកប្រាក់សរុបចំនួន ៤០ ៦៧៦,៨៦ដុល្លារអាមេរិក នៅធនាគារជាតិនៃកម្ពុជា និងធនាគារអេស៊ីលីដា ភីអិលស៊ី
- បានបង់រួចសម្រាប់ឆ្នាំ២០១៧ (២០១៧-២០១៨) នូវទឹកប្រាក់សរុបចំនួន ៤០ ២៧៤,១០ដុល្លារអាមេរិក នៅធនាគារជាតិនៃកម្ពុជា និងធនាគារអេស៊ីលីដា ភីអិលស៊ី
- បានបង់រួចសម្រាប់ឆ្នាំ២០១៥ និង២០១៦ (២០១៤-២០១៥ និង២០១៥-២០១៦) នូវទឹកប្រាក់សរុបចំនួន ៧៩ ៣៥៥,៩០ដុល្លារអាមេរិក នៅធនាគារជាតិនៃកម្ពុជា និងធនាគារកាណាឌីយ៉ា ក.អ កម្ពុជា

**១២.ទំនាស់ដីធ្លី និងការដោះស្រាយៈ** មាន ☑ គ្មាន ☐ បើមានស្នើអត្ថាធិប្បាយពីៈ

- **ក-ទីតាំងទំនាស់ស្ថិតនៅអនុតំបន់ណា? ទំហំដីទំនាស់ប៉ុន្មានហិកតា? ចំណុចនិយាមកា?**

បញ្ហាដីធ្លីដែលកំពុងដំណើការដោះស្រាយ និងស្នើសុំយន្តការដោះស្រាយពីស្ថាប័នមានសមត្ថកិច្ចថ្នាក់ក្រោមជាតិដើម្បីដឹកនាំសម្របសម្រួលមានសរុបចំនួន ១៤៥ករណី (ប៉ះពាល់នឹងតំបន់សម្បទានផ្ទៃដីជាង ១៥០ហិកតា និងក្រៅសម្បទានផ្ទៃដីប្រមាណ ៥,៥ហិកតា) ដែលក្នុងនោះមាន ១២៣ករណី ពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ចដែលបានចុះបញ្ជី និងរៀបចំអនុបយោគរួចរាល់ និង២២ករណី ពាក់ព័ន្ធនឹងតំបន់ទ្រនាប់អូរដែលក្នុងរក្សាទុកដើម្បីនិយ័តកម្មប្រភពទឹក និងគុណភាពទឹក។ បញ្ហាដីធ្លីចំនួន ១២៣ករណី បណ្តាលមកពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីមានលក្ខណៈប្រព័ន្ធរបស់ក្រុមការងារចុះបញ្ជីធ្លីមានលក្ខណៈជាប្រព័ន្ធរបស់ខេត្តកំពង់ស្ពឺ ដែលបានធ្វើចុះវាស់វែង កំណត់ព្រំប្រទល់ និងវិនិច្ឆ័យក្បាលដីជូនប្រជាជន និងទំនាស់ព្រំប្រទល់ ស្ថិតនៅក្នុងភូមិសាស្ត្រឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ ដោយឡែក បញ្ហាដីធ្លីចំនួន ២២ករណីផ្សេងទៀត ជាដីដែលប្រជាជនទាមទារដើម្បីអាស្រ័យផលដែលស្ថិតនៅក្នុងតំបន់ទ្រនាប់អូរដែលក្រុមហ៊ុនរក្សាទុក និងស្ថិតនៅក្រៅព្រំតំបន់សម្បទានដីសេដ្ឋកិច្ច (ជូនភ្ជាប់ផែនទីតំបន់ទំនាស់ដីធ្លី និងបញ្ជីឈ្មោះអ្នកទាមទារ)។

- **ខ-ថ្ងៃ/ខែ/ឆ្នាំកើតទំនាស់ មូលហេតុទំនាស់ និងឯកសារពាក់ព័ន្ធ**

បញ្ហាដីធ្លីទាំងមានការពាក់ព័ន្ធនឹងតំបន់សម្បទានដីសេដ្ឋកិច្ច និងក្រៅតំបន់សម្បទានទាំង ១៤៥ករណី ក្នុងនោះ ឆ្នាំ២០១៧៖០១ករណី ២០១៨៖០៥ករណី ២០១៩៖១២៣ករណី ២០២០៖១៥ករណី និងឆ្នាំ២០២១៖០១ករណី (ផ្ទៃដីប៉ះពាល់សរុប៖ ១៥៥,៥ហិកតា ក្នុងនោះសម្បទានដីសេដ្ឋកិច្ចទំហំជាង ១៥០ហិកតា និងតំបន់ក្រៅសម្បទានដីសេដ្ឋកិច្ចប្រមាណ ៥,៥ហិកតា ស្ថិតនៅតំបន់ទ្រនាប់អូរដែលក្រុមហ៊ុនរក្សាទុក) ដែលបាននឹងកំពុងដំណើការដោះស្រាយកម្រិតមូលដ្ឋានជាមួយប្រជាជន អាជ្ញាធរភូមិ ឃុំ និងមន្ត្រីរដ្ឋបាលព្រៃឈើប្រចាំការ។ ទោះបីជាយ៉ាងណាក៏ ការដោះស្រាយនៅមិនទាន់បញ្ចប់ និងទទួលបានជោគជ័យនៅឡើយ ព្រោះប្រជាជនមូលដ្ឋានមានបារម្ភពីភាពត្រឹមត្រូវ ឬសុក្រឹត្យភាពនៃការដោះស្រាយដែលផ្តួចផ្តើមឡើងដោយក្រុមហ៊ុន។ ចំពោះលិខិតនៃការកាន់កាប់ដីធ្លីភាគច្រើនប្រជាជនមានតែបង្កាន់ដៃទទួលស្គាល់សិទ្ធិ (បញ្ជាក់ដោយអាជ្ញាធរឃុំ) និងមួយចំនួនទៀតមិនមាននោះទេ។

- **គ-វិធានការដោះស្រាយ និងលទ្ធផលដោះស្រាយ**

ពោះករណីបញ្ហាដីធ្លីទាំងអស់ត្រូវបានធ្វើការកំណត់នូវឫសគល់នៃបញ្ហា និងកត់ត្រានៅក្នុងតារាងតាមដានបញ្ហារបស់ក្រុមហ៊ុន។ នៅក្នុងដំណើរការកំណត់ឫសគល់នៃបញ្ហានៃទំនាស់ដីធ្លីនីមួយៗ ក្រុមហ៊ុនធ្វើឡើងដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន (ភូមិ ឃុំ) រដ្ឋបាលព្រៃឈើ ប្រជាជនពាក់ព័ន្ធ ដើម្បីពិនិត្យផលប៉ះពាល់ជាក់ស្តែងនៅទីវាល ប្រមូលឯកសារនៃការកាន់កាប់ដីធ្លី និងឯកសារពាក់ព័ន្ធផ្សេងទៀត។ គិតត្រឹមត្រីមាសទី១ ឆ្នាំ២០២១ ក្រុមហ៊ុនមិនត្រឹមតែបានធ្វើការដោះស្រាយ សម្របសម្រួលបញ្ហាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានអនុវត្តច្បាប់ក្នុងកម្រិតមូលដ្ឋានដោយ ដាក់បណ្តឹងទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី និងស្ថាប័នពាក់ព័ន្ធ ជំទាស់លើលទ្ធផលនៃវិនិច្ឆ័យក្បាលដីសម្រាប់ចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ បានជួបប្រជុំជាមួយប្រធានក្រុមការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធថ្នាក់ស្រុក ដើម្បីស្វែងយល់ពីបញ្ហានិងកំណត់ទិសដៅដោះស្រាយបន្ត និងបានកំណត់មុខសញ្ញាអ្នកទាមទារ ទីតាំងទាមទារ (ទំនាស់) និងផែនទី ដើម្បីមានមូលដ្ឋានក្នុងរាយការណ៍ជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីមានអន្តរាគមន៍។

បន្ថែមលើនេះទៀត តាមរយៈរបាយការណ៍នៃកិច្ចប្រជុំក្រុមការងារអន្តរឃុំ (រស្មីសាមគ្គី និងក្រាំងដីវ៉ាយ) នៅថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០២១ បាន

- បញ្ហាដីធ្លីដែលស្ថិតនៅលើដីរដ្ឋដែលប្រជាជនមូលដ្ឋានបានដាក់ស្នើសុំកាត់ឆ្វៀលតាមអនុសាសន៍ថ្ងៃទី ៣ ខែកក្កដា ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាល ត្រូវរង់ចាំការសម្រេចពីរាជរដ្ឋាភិបាល
- រៀបចំរបាយការណ៍ស្តីពីបញ្ហាដីធ្លីជាន់នឹងសម្បទានដីសេដ្ឋកិច្ចទាំង ១២៣ករណី គោរពជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត តាមរយៈរដ្ឋបាលស្រុកទាំងពីរដើម្បីស្នើសុំវិធានការដោះស្រាយ

**១៣.ទំហំដីឆ្វៀលតាមបទបញ្ជា ០១៖**..................គ្មាន.................. (ស្នើផ្តល់ឯកសារ)

**១៤.លទ្ធផលអនុវត្តខ្លឹមសារ ស.ជ.ណ តាមរបាយការណ៍របស់គណៈកម្មការអន្តរក្រសួង**(៧)។

| លេខលិខិត សជណ | ខ្លឹមសារសម្រេចរបស់ ស.ជ.ណ | លទ្ធផលអនុវត្តបានតាមខ្លឹមសារ សជណ |
|---|---|---|
| លិខិតលេខ. ១០៨៤ សជណ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី | អនុញ្ញាតអោយក្រុមហ៊ុនហ្វ្រេនឌីសធីមបើរ អិលធីឌី បន្តនីតិវិធីដោះស្រាយផលប៉ះពាលជា មួយ ប្រជាជន និងចុះកិច្ចសន្យាឡើងវិញដោយបន្ថយរយៈពេលពី៧០មកត្រឹម ៥០ឆ្នាំវិញ | • បានចុះបញ្ជីដីរួចរាល់<br>• ធ្វើអនុបយោគរួចរាល់ពីដីសាធារណៈ មកជាដីឯកជនរបស់រដ្ឋ<br>• ចុះកិច្ចសន្យាកែតម្រូវ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០១៧<br>• បញ្ចប់ផែនការមេថ្មី និងអនុម័តរួចរាល់ |

(៧) គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច

**១៥.ការអនុវត្តន៍បន្ទាប់ពីការណែនាំរបស់ក្រសួង ឬខេត្ត ៖** (ស្នើផ្តល់ឯកសារ)

| ល.រ | លេខលិខិត និងខ្លឹមសារ | លទ្ធផលអនុវត្តបានតាមការណែនាំរបស់ក្រសួង |
|---|---|---|
| ១ | លិខិតជូនដំណឹងលេខ ១៩៨២ កសក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ស្តីពីកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនរដ្ឋ ឆ្នាំ២០២០ | ក្រុមហ៊ុនបានធ្វើការឆ្លើយតបគណៈកម្មការអន្តរក្រសួងចុះពិនិត្យ និងប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចបង់ចូលថវិការដ្ឋ តាមរយៈលិខិតលេខ ០៣/២១ ហ្វ្រ.ធ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១ |

**១៦.សំណូមពររបស់ក្រុមហ៊ុន ៖**

តាមរយៈការបញ្ជាក់ខាងលើ ក្រុមហ៊ុនហ្វ្រែនឌីស ធីមបើរ អិលធីឌី នៅមានសកម្មភាពមួយចំនួនដែលកំពុងជាប់គាំង និងរង់ចាំនីតិវិធីពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានកិច្ចអន្តរាគមន៍ ដូចខាងក្រោម៖

- ស្នើសុំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយរដ្ឋបាលខេត្ត ឬស្រុក ដើម្បីបន្តនីតិវិធីដោះស្រាយបញ្ហាដីធ្លីជាមួយប្រជាជនមូលដ្ឋាន (១២៣ករណីជាន់នឹងសម្បទានដីសេដ្ឋកិច្ច និង២២ករណីនៅក្នុងតំបន់ទ្រនាប់អូរ ឬតំបន់ការពារ)
- ស្នើសុំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយអាជ្ញាធរដែនដីមូលដ្ឋានផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ដែលឆ្លងកាត់ចេញចូលអាស្រ័យផល-អនុផលព្រៃឈើក្នុងដីសម្បទានសេដ្ឋកិច្ច ថែរក្សាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន (បង្គោលរបង លួរបន្ទារ និងករណីលួចដើមឈើ) និងចេញចូលតាមច្រកប៉ុស្ដិ៍យាម
- ស្នើសុំបន្ត និងពង្រឹងការចុះណែនាំអប់រំប្រជាពលរដ្ឋពីបញ្ហាបង្ករភ្លើងឆេះព្រៃ វាលស្មៅ ឬព្រៃតាមទ្រនាប់អូរ ដើម្បីជាប្រយោជន៍ចំណីសត្វពាហនៈឬគោលបំណងផ្សេងដែលបង្កជាហានិភ័យធ្ងន់ធ្ងរ
- ស្នើសុំឱ្យមានវិធានការផ្លូវច្បាប់តឹងរឹងបំផុតចំពោះអ្នកបរបាញ់ ដាក់អន្ទាក់សត្វព្រៃ និងអ្នកដុតបំផ្លាញព្រៃឈើ ឬចម្ការឈើដាំរបស់ក្រុមហ៊ុនដោយចេតនា

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅភ្នំពេញ ថ្ងៃទី........ ខែ............ ឆ្នាំ២០២១

**ប្រធានប្រតិបត្តិ**